# ពេលវេលា ត្រូវធ្វើ បដិវត្តន៍ !

Le temps est à la révolution !

នៅពេលណា ដែលអំណាចផ្តាច់ការ យកអំពើឃាតកម្ម ជាមធ្យោបាយ សំរាប់ត្រួតត្រា ប្រជាពលរដ្ឋ នៅពេលនោះ អ្នកស្នេហាជាតិ ត្រូវរួមគ្នា បង្កើត ចលនា បដិវត្តន៍ ព្រោះតាម ច្បាប់ធម្មជាតិ អំណាចផ្តាច់ការ តែងតែ ជាកត្តា បង្កើត បដិវត្តន៍។ កម្លាំង បដិវត្តន៍ អាចនឹងរំលាយរបប អំណាចផ្តាច់ការ ក្នុងរយៈពេលតែមួយថ្ងៃបាន បើកម្លាំងនេះ ផ្ទុះឡើង នៅក្នុង ឱកាស ដ៏ល្អមួយ (le moment opportun) ព្រោះ ឱកាសល្អនេះឯងហើយ ជា អ្នកបង្កើត បដិវត្តន៍។ តែ យើង ត្រូវដឹងថា បដិវត្តន៍ មិនមែន សុទ្ធជា ផ្លូវសំរាប់ ដើរសំដៅត្រង់ ទៅរក លទ្ធិប្រជាធិបតេយ្យ នោះឡើយ ព្រោះយើងដឹងថា មាន អ្នកឆ្លៀតយក **ប្រជាចលនា**[1] មកប្រើដើម្បី ស្វែងរកប្រយោជន៍ផ្ទាល់ ផ្ទុយពីឆន្ទៈ ប្រជាពលរដ្ឋ ដោយប្រើឧបាយកល បោកប្រាស់មហាជន។ ម្យ៉ាងមួយទៀត ត្រូវមើលឃើញឲច្បាស់ នូវសំទុះ **ប្រជាកោលាហល**[2] ហើយ មិនត្រូវយល់ច្រឡំ អោយសោះថា កុបកម្ម របស់ ប្រជាជន មួយចំនួនធំ ជាការចាប់ផ្តើម នៃបដិវត្តន៍។ ការយល់ច្រឡំ នាំឲ កម្លាំង កុបកម្ម ខ្វះ ការពិចារណារ ឲបានច្បាស់លាស់ នូវគំនិត ប្រឆាំង ឬ ទាមទារ របស់ខ្លួន ដូច្នេះ អ្នកដឹកនាំ ប្រជាចលនា ត្រូវមាន អំណត់ រង់ចាំ វិជ័យ នៃ មតិ ក្នុងគោលបំណងរួមរបស់ បាតុករ ប្រកបដោយ និស្ស័យ (la certitude)។ គុណធម៌ (la vertu) របស់ បដិវត្តន៍ គឺ ពេលវេលា របស់ អំណត់ នេះឯង។

បដិវត្តន៍ ពិតប្រាកដ ត្រូវចាំបាច់ បង្ហាញ លក្ខណៈ ជា «កម្លាំង ប្រជាពលរដ្ឋ» ដើម្បីការពារសេរីភាព ពលរដ្ឋ (citoyen) ម្នាក់ៗ ដែលជា សិទ្ធិ របស់ គេ និង ប្រយោជន៍ជាតិ ដោយមានច្បាប់ធានា។ បដិវត្តន៍ មានលក្ខណៈបែបនេះ ទើបអាចមាន ធម្មានុរូប ផ្អែកលើ កម្លាំងពីរ ដើរសំដៅទៅរកកន្លែង តែមួយគឺ **បំណងតែមួយ** និង **ភាពពេញលក្ខណៈច្បាប់** (ច្បាប់រដ្ឋ, ច្បាប់ធម្មជាតិ និង ច្បាប់សាកលនៃ សិទ្ធិមនុស្ស)។ នៅស្រុកខ្មែរ ក្នុងឆ្នាំ ២០១៣ មានកើត ប្រជាចលនា ពិតប្រាកដ ទាមទាររកយុត្តិធម៌ អោយ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្ស ឈ្នះឆ្នោត ព្រោះខ្លួនជា ម្ចាស់ឆ្នោត។ ពេលនោះ ប្រជាកោលហលមានកើតឡើង ដែលអាចចាត់ទុកបាន ជាការផ្តើមមួយនៃបដិវត្តន៍ ពិត ព្រោះ ប្រជាចលនា មានគោលបំណងតែមួយហើយស្របនិងធម្មជាតិមនុស្ស។ តែ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ខ្វះអំណត់ ខ្លួនឯង បែជាក្បត់ឆន្ទៈ ប្រជាពលរដ្ឋ ធ្វើការចរចារ ជាមួយ គណបក្សកាន់អំណាច ដើម្បី រកប្រយោជន៍ផ្ទាល់៖ ពួកគេ លើកយក «សន្តិភាព» ជា ហេតុផល តម្រូវ ឲមានការចរចារ ក្នុងនាម នៃការផ្សះផ្សាជាតិ។

តែពួកគេភ្លេចគិតថា សន្តិភាព មិនមែន ជាលទ្ធិប្រជាធិបតេយ្យ ព្រោះនៅក្នុង **ការចរចារ លៃតាមប្រយោជន៍**[3] អាចរក្សា សន្តិភាព បានពិត តែក្នុងសន្តិភាពនេះ មិនអាច បន្ថយ នូវសេចក្តីខ្លាច, គម្លាន របស់ប្រជាពលរដ្ឋ និង អំពើ ហឹង្សា របស់ អ្នកកាន់អំណាច បាននោះឡើយ។ ជា

[1] ប្រជាចលនា= Le mouvement populaire។
[2] ប្រជាកោលាហល= L’agitation populaire។
[3] ចរចារ លៃតាមប្រយោជន៍= La négociation réglée ou l’arrangement។

ការពិតហើយ ថា សម្លេងកំហឹង នៃ ប្រជាពលរដ្ឋ មិនមែនជាកម្លាំង នៃ វិចារណញ្ញាណ តែ បើ សូរសៀង នេះ មាន នៅក្នុង លទ្ធិប្រជាធិបេតយ្យ វាអាចសំថៃ នៅក្នុងនគរ នូវ ហានិភ័យ ដែលអាច កើតចេញមកពី បដិវត្តន៍ ដ៏កម្រោលមួយ ដូចមាន នៅក្នុងសម័យ ខ្មែរក្រហម។

ហេតុនេះឯង នៅស្រុកខ្មែរ នាបច្ចុប្បន្ននេះ ជា ពេលវេលា ត្រូវធ្វើបដិវត្តន៍ ដើម្បី លើកដំកើង លទ្ធិប្រជាធិបតេយ្យ តាមផ្លូវ បញ្ញា ដែលជា កម្លាំងជំរុលចិត្ត អោយមាន គំនិត នៃលទ្ធប្រជាធិបតេយ្យ។ ការយល់ដឹងច្បាស់ អំពី លទ្ធិប្រជាធិបតេយ្យ នាំឲ ពលរដ្ឋម្នាក់ៗ មាន សម្បទាន (aptitude) ចេះគោរពខ្លួនឯង ដោយខ្លួនឯង ហើយ ចូលរួម ធ្វើសហប្រតិបត្តិការប្រកបដោយ សម្បជញ្ញ ក្នុងកិច្ចការសាធារណៈ ដើម្បី ការសម្រេច នូវ ឧត្តមគោលបំណង របស់ប្រជាជាតិ គឺ សេចក្តីចំរើន នៃប្រជាពលរដ្ឋ។ បដិវត្តន៍ តាមផ្លូវ បញ្ញា ត្រូវប្រើ មធ្យោបាយគ្រប់បែបយ៉ាង ក្នុងគោលគោលបំណងតែមួយ និង នៅក្នុង **គុណធម៌នយោបាយ**[4] សមស្របតាម**សីលធម៌ នៃ មនុស្សជាតិ**[5]។ គុណធម៌នយោបាយ សំរាប់ជនជាតិខ្មែរ នាបច្ចុប្បន្ននេះ គឺ ការទទួលខុសត្រូវ លើវាសនា របស់ខ្លួន ដោយខ្លួនឯង ដូច្នេះ ពលរដ្ឋខ្មែរ ម្នាក់ៗ ត្រូវមាន ជាចាំបាច់ ជាករណីកិច្ច នូវ សម្ថភាព ឆ្លើយតប ជាវិជ្ជមាន គ្រប់ កាលៈទេសៈ ដែលនាំមកនូវជោគ (chance)ដើម្បី រកប្រយោជន៍ ជូន ប្រជាជាតិខ្មែរ។ ជោគនេះ គឺ ប្រជាជនខ្មែរទូទៅ ចាប់ផ្តើម មាន **ការយល់ដឹងរួម ជាសាធារណៈ**[6] អំពីភាពចង្រៃ នៃរបបផ្តាច់ការ និង អំពើក្បត់ ឆន្ទៈប្រជាពលរដ្ឋរបស់ អ្នកដឹកនាំ នៃគណបក្សសង្គ្រោះជាតិ។

ហេតុនេះហើយ នៅស្រុកខ្មែរ គឺត្រូវដល់ ពេលវេលា ត្រូវធ្វើបដិវត្តន៍ ដើម្បី ជួយ លទ្ធិប្រជាធិបតេយ្យ ឲមានជីវិតខ្ពង់ខ្ពស់ ដើម្បី ការលូតលាស់ នៃ ប្រជាជាតិ និង សុភមង្គល នៃប្រជាពលរដ្ឋខ្មែរ ព្រោះលទ្ធិប្រជាធិបតេយ្យ ជាអានាគត នៃមនុស្សលោក។

**ឧប សៅ សង្ហា**

**ថ្ងៃទី១ តុលា ឆ្នាំ ២០១៤**

---

4 គុណធម៌នយោបាយ= La vertu politique។
5 សីលធម៌ នៃមនុស្សជាតិ= La morale de l'humanité។
6 ការយល់ដឹងរួម ជាសាធារណៈ= La raison publique។